# មេរៀនទី ៨៧៖ ព្រះបានជ្រើសរើសដាវីឌដើម្បីជំនួសសូល

[១ សាំយូអែល ១៦៖១-១៣](#)

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/l0w3Na07H_0

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/C5Azf2iuxOg

**គោលបំណង៖** ព្រះជ្រាបដឹងពីយើងគ្រប់ៗគ្នា។

**ខគម្ពីរចងចាំ៖** *សុភាសិត ២១៖២ "គ្រប់ទាំងផ្លូវរបស់មនុស្ស សុទ្ធតែត្រឹមត្រូវនៅភ្នែកខ្លួន តែព្រះយេហូវ៉ាទ្រង់ថ្លឹងចិត្តវិញ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. បើអ្នកសប្បាយក្នុងព្រះយេស៊ូវ https://youtu.be/SsldqdQB-9U

២. ព្រះយេស៊ូវស្រលាញ់ខ្ញុំណាស់ https://youtu.be/R4MEw0jzZ_E

៣. ព្រះនឹងរៀបចំផ្លូវ https://youtu.be/pKmid-FNhhw

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «ឈ្មោះមិត្តភក្តិរបស់អ្នក»**



១. ចែកកុមារជា២ក្រុម

២. រើសតំណាងក្រុមម្នាក់មួយ

៣. តំណាងក្រុមនីមួយៗត្រូវហៅឈ្មោះ កុមារឲ្យបាន៥នាក់ ឬច្រើនជាងនឹងតាមដែលគ្រូចង្អុល។ ក្រុមណាដែលអាចហៅឈ្មោះកុមារផ្សេងទៀតបានច្រើនជាងគេគឺជាអ្នកឈ្នះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់ប្រាប់កុមារថា ទោះប្បីជាយើងមិនស្គាល់ឈ្មោះអ្នកគ្រប់គ្នា នៅក្នុងបន្ទប់នេះ ឬនៅក្នុងពិភពលោកនេះក៏ដោយ ក៏ព្រះស្គាល់មនុស្សគ្រប់គ្នាដែរ! ព្រះស្គាល់យើងគ្រប់ៗ គ្នា!

## ៤. ការណែនាំមេរៀន

ឲ្យកុមារប្រាប់ពីអ្វីគ្រប់យ៉ាងដែលពួកគេបានស្គាល់ពីអ្នក(គ្រូសាលាថ្ងៃអាទិត្យ)។ ប្រហែលជាកុមារនឹងអាចប្រាប់ថា គ្រូជាស្រីឬជាប្រុស គ្រូខ្ពស់ គ្រូរៀបការហើយ ឬក៏នៅ។ បន្ទាប់ពីពួកគេបាន ប្រាប់គ្រប់យ៉ាងដែលពួកគេបានស្គាល់ពីអ្នករួចហើយ សូមប្រាប់ពួកគេពីអ្វីដែលជាព័ត៌មានថ្មីសំរាប់កុមារ។ ពន្យល់កុមារថា ប្អូនអាចនឹងគិតថា ប្អូនដឹងគ្រប់យ៉ាងពីនរណាម្នាក់ ប៉ុន្តែមានអ្វីៗជាច្រើន ដែលយើងមិនបានដឹង។ មានតែព្រះទេដែលដឹងគ្រប់យ៉ាងដែលទាក់ទងនឹងយើង! ថ្ងៃនេះយើងនឹងសិក្សាអំពី ការជ្រើសរើសរបស់ព្រះ ចំពោះស្តេចទី២ របស់សាសន៍អ៊ីស្រាអែល។ ហោរ៉ា សាំយូអែលបានដឹងថា ព្រះអាចមើលធ្លុះដល់ជំរៅចិត្តរបស់យើង ពីព្រោះព្រះជ្រាបដឹងគ្រប់យ៉ាងទាំងអស់អំពីយើង។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

មានពេលមួយនៅក្នុងប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែល នៅពេលដែលប្រជាជនត្រូវការជ្រើសរើសស្ដេចថ្មីមួយទៀត។ ជាធម្មតាស្ដេចថ្មីគឺត្រូវតែជារាជបុត្ររបស់ស្ដេចចាស់ដែលបានសោយរាជ្យកន្លងមក។ ប៉ុន្តែស្ដេចអ៊ីស្រាអែលដែលមានឈ្មោះថា សូលមិនស្ដាប់បង្គាប់ព្រះជាច្រើនលើកជាច្រើនសារ ហើយព្រះបានសំរេចចិត្តជ្រើសរើសមនុស្សម្នាក់ទៀតដែលមិនមែនជាបុត្ររបស់ស្ដេចសូលមកធ្វើជាស្ដេចជំនួសវិញ។

ព្រះបានប្រាប់ទៅសាំយូអែលឲ្យទៅទីក្រុងបេថ្លេហឹមដែលអ៊ីសាយកំពុងរស់នៅ និងរៀបចំធ្វើយញ្ញបូជាថ្វាយព្រះនៅទីនោះ។ សាំយូអែលបានធ្វើតាមអ្វីដែលព្រះបង្គាប់ឲ្យធ្វើ។ គាត់បានទៅស្រុកកំណើតរបស់អ៊ីសាយ ហើយកូនទាំង៧របស់អ៊ីសាយបាននៅទីនោះដែរ។ កូនម្នាក់ៗរបស់អ៊ីសាយត្រូវតែឆ្លងកាត់ការពិចារណារបស់សាំយូអែល។

សាំយូអែលគិតថាកូនប្រុសច្បង ដែលគាត់មើលឃើញប្រាកដជាអ្នកដែលព្រះបានរើសធ្វើជាស្ដេច។ ព្រោះគាត់ខ្ពស់ស្រលះ ហើយរូបរាងសង្ហា ប៉ុន្តែព្រះមានបន្ទូលថា **១ សាំយូអែល ១៦:៧** "តែព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា កុំឲ្យមើលតែឫកពាខាងក្រៅ ឬកំពស់ខ្លួននោះឡើយ ដ្បិតអញមិនទទួលអ្នកនេះទេ ពីព្រោះព្រះទ្រង់មិនទតចំពោះសេចក្ដី ដែលមនុស្សលោកពិចារណាមើលទេ ឯមនុស្សលោក តែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្តវិញ។"

កូនប្រុសទាំង៧របស់អ៊ីសាយបានឆ្លងកាត់ការពិចារណារបស់សាំយូអែលទាំងអស់ ប៉ុន្តែព្រះមិនបានរើសនរណាម្នាក់ធ្វើជាស្ដេចថ្មីនោះទេ។ សាំយូអែលបានសួរទៅអ៊ីសាយថា មានកូនប្រុសផ្សេងទៀតទេ។ អ៊ីសាយបានឆ្លើយតបវិញថា កូនប្រុសពៅបានចេញទៅចំការដើម្បីមើលចៀម។ កូនពៅជាអ្នកគង្វាលចៀម សាំយូអែលបានប្រាប់ឲ្យអ៊ីសាយទៅនាំកូនពៅឲ្យមកជួបគាត់។ នៅពេលដែលកូនពៅបានធ្វើដំណើរចេញពីវាលស្មៅមកភ្លាម ព្រះបានមានបន្ទូលប្រាប់សាំយូអែលថា បុរសម្នាក់នេះហើយ ដែលនឹងមកធ្វើជាស្ដេចថ្មីរបស់អ៊ីស្រាអែល។ ដូច្នេះគាត់ក៏បានចាក់ប្រេងលាបលើក្បាលកូនពៅរបស់អ៊ីសាយដែលមានឈ្មោះថា ដាវីឌនោះ។ ដាវីឌក៏បានក្លាយទៅជាស្ដេចថ្មីតាំងពីពេលនោះមក។

ព្រះបានបង្កើតយើង ហើយទ្រង់ជ្រាបដឹងពីយើងគ្រប់ៗគ្នា។ ព្រះអង្គមានផែនការសំរាប់ដាវីឌ។ ព្រះបានជ្រាបដឹងថា ដាវីឌនឹងក្លាយទៅជាស្ដេចល្អ។ ព្រះមានផែនការសំរាប់យើងគ្រប់គ្នាដែរ។ ព្រះដឹងថាអ្វីដែលល្អប្រសើរសំរាប់យើងគ្រប់គ្នា ពីព្រោះព្រះបានទតឃើញពីជំរៅចិត្តរបស់យើង។ ព្រះពិតជាជ្រាបដឹងអ្វីដែលប្រសើរសំរាប់យើងរាល់គ្នា។

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាបុត្រារបស់ស្ដេចសូលមិនអាចក្លាយជាស្ដេចបន្ទាប់របស់អ៊ីស្រាអែល?
*(ដោយសារស្ដេចសូលមិនស្ដាប់បង្គាប់ព្រះជាច្រើនដង។)*
២. តើព្រះបានចាត់ហោរ៉ាសាំយូអែលទៅរកស្ដេចថ្មីរបស់អ៊ីស្រាអែលនៅក្នុងគ្រួសារណា?
*(នៅក្នុងគ្រួសារអ៊ីសាយ អ៊ីសាយគឺជាឪពុករបស់ដាវីឌ)*
៣.ហេតុអ្វីបានជាព្រះមិនជ្រើសរើសកូនប្រុសទាំងប្រាំពីរនាក់ដែលនៅក្នុងផ្ទះ?
*(ដោយសារព្រះទ្រង់ជ្រាបពីចិត្តគេ ហើយពួកគេមិនល្អគ្រប់គ្រាន់ដើម្បីធ្វើជាស្ដេចនោះទេ)*
៤.តើដាវីឌកំពុងធ្វើអ្វី ពេលបងប្អូននៅក្នុងផ្ទះ? *(គាត់នៅវាលមើលហ្វូងចៀម)*
៥.តើនរណាត្រូវបានជ្រើសរើសជាស្ដេចអ៊ីស្រាអែលបន្ទាប់ពីស្ដេចសូល? *(ដាវីឌ)*

**៧. ល្បែងកំសាន្ត “ស្តេចបញ្ជា”**



១. ពន្យល់កុមារថា ពួកគេត្រូវតែធ្វើកាយវិការតាមគ្រូ នៅពេលដែល គ្រូនិយាយថា “ស្តេចបញ្ជាឲ្យ…..”

២. ឧទាហរណ៍៖ នៅពេលដែលគ្រូនិយាយថា “ស្តេចបញ្ជាឲ្យអ្នកប៉ះ ក្បាលរបស់អ្នក” ដូច្នេះកុមារត្រូវតែប៉ះក្បាលរបស់ពួកគេ។

៣. ប៉ុន្តែប្រសិនបើគ្រូមិនបាននិយាយពាក្យថា “ស្តេចបញ្ជា” ទេនោះ កុមារមិនត្រូវធ្វើតាមគ្រូនិយាយនោះទេ។

៤. ឧទាហរណ៍៖ ពេលគ្រូនិយាយថា “លោត” នោះកុមារមិនត្រូវលោតនោះទេ ហើយក៏មិនត្រូវដូរកាយវិការអ្វីទាំងអស់។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ស្តេចគឺមានអំណាចប្រាប់មនុស្សឲ្យធ្វើអ្វីក៏បាន។ ប៉ុន្តែព្រះពិតប្រាកដនោះគឺជាស្តេចលើសអស់ទាំងស្តេច។ ដូច្នេះ យើងទាំងអស់គ្នាត្រូវតែស្តាប់ និងដើរតាមព្រះ ដែលជាស្តេចរបស់យើង។

**៨. ខគម្ពីរចងចាំ**

**សុភាសិត ២១៖២** *“គ្រប់ទាំងផ្លូវរបស់មនុស្ស សុទ្ធតែត្រឹមត្រូវនៅភ្នែកខ្លួន តែព្រះយេហូវ៉ាទ្រង់ថ្លឹងចិត្តវិញ។”*

**៩. ហាត្ថកម្ម “ព្រះអាចមើលឃើញពីជម្រៅចិត្តរបស់យើង - វ៉ែនតា”**

សម្ភារៈដែលត្រូវការ៖ បោះពុម្ពវ៉ែនតាក្រដាសនៅទំព័រខាងក្រោម កូល័រទៀន កន្ត្រៃ និងកាវ



១. បោះពុម្ពគំរូវ៉ែនតា ហើយឲ្យកុមារម្នាក់ៗមួយឈុត។

២. ឱ្យកុមារតុបតែងលើវ៉ែនតាទាំងអស់នោះ។

៣. នៅពេលដែលពួកគេធ្វើរួច កាត់វ៉ែនតា និងដងចេញ។ ភ្ជាប់ដងទៅនឹងវ៉ែនតា។



៤. ពាក់វ៉ែនតាហើយនិយាយថា “ព្រះស្គាល់ខ្ញុំ! ព្រះអាចមើលឃើញចិត្តខ្ញុំ! ”

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវមិនខ្វល់ថាយើងមើលទៅដូចជាគ្រីស្ទបរិស័ទល្អទៅលើរូបរាងខាងក្រៅទេ។ អ្វីដែលព្រះយេស៊ូវចង់បានបំផុតគឺឲ្យចិត្តយើងលះបង់ទាំងស្រុងទៅចំពោះទ្រង់។ សូមអាន **សាំយូអែលទី១ ១៦:៧** ។ នៅ ពេលដែលអ្នកបានធ្វើការងារនៅក្នុងក្រុមជំនុំទោះជានៅក្នុងចិត្តរបស់អ្នកមិនពេញចិត្តក៏ដោយ ដើម្បីកុំឲ្យមើលទៅអាក្រក់នៅមុខអ្នកដទៃ តើអ្នកគិតថាអ្នកមានកិត្តិយសប៉ុណ្ណា នៅពេលដែលមានវត្តមានរបស់ព្រះគង់នៅក្បែរពេលអ្នកធ្វើការងារទាំងអស់នោះ? ព្រះបានធ្វើការអស្ចារ្យជាច្រើនសំរាប់យើង! សូមរក្សាចិត្តរបស់អ្នកដោយផ្តោតចិត្តរបស់អ្នកជាមួយព្រះរាល់ថ្ងៃនេះ។

# ព្រះអាចមើលឃើញពីជម្រៅចិត្តរបស់យើង- វ៉ែនតា



